ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ...០១៧|២៤................ក.ប/ស.ជ.ល.ម.ព

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន
## សម្រាប់ពលករជំនាញដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញ ឱ្យបានជ្រាបថាអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុនសម្រាប់ពលករជំនាញ តាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT) ក្នុងគម្រោងពលករជំនាញ ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

| ល.រ | ប្រភេទតេស្ត | កាលបរិច្ឆេទធ្វើតេស្ត | មណ្ឌល | តម្លៃចុះឈ្មោះ |
|---|---|---|---|---|
| ១ | ផ្នែកថែទាំ | ថ្ងៃទី២ និង២៤ ខែសីហា ឆ្នាំ២០២៤<br>ថ្ងៃទី៣-៥ ខែកញ្ញា ឆ្នាំ២០២៤<br>ថ្ងៃទី៧, ៨, ១០, ១២ និង១៤ ខែកញ្ញា ឆ្នាំ២០២៤<br>ថ្ងៃទី១៧-២០ ខែកញ្ញា ឆ្នាំ២០២៤<br>ថ្ងៃទី២៧-២៩ ខែកញ្ញា ឆ្នាំ២០២៤ | វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI) | ១៤ដុល្លារ |
| ២ | ផ្នែកកសិកម្ម | ថ្ងៃទី២ និង២៤ ខែសីហា ឆ្នាំ២០២៤<br>ថ្ងៃទី៣-៥ ខែកញ្ញា ឆ្នាំ២០២៤<br>ថ្ងៃទី៧, ៨, ១០, ១២ និង១៤ ខែកញ្ញា ឆ្នាំ២០២៤<br>ថ្ងៃទី១៧-២០ ខែកញ្ញា ឆ្នាំ២០២៤<br>ថ្ងៃទី២៧-២៩ ខែកញ្ញា ឆ្នាំ២០២៤ | | ៣៣ដុល្លារ |
| ៣ | ផ្នែកការងារនៅភោជនីយដ្ឋាន | ថ្ងៃទី២ និង២៤ ខែសីហា ឆ្នាំ២០២៤<br>ថ្ងៃទី៣-៥ ខែកញ្ញា ឆ្នាំ២០២៤<br>ថ្ងៃទី៧, ៨, ១០, ១២ និង១៤ ខែកញ្ញា ឆ្នាំ២០២៤<br>ថ្ងៃទី១៧-២០ ខែកញ្ញា ឆ្នាំ២០២៤<br>ថ្ងៃទី២៧-២៩ ខែកញ្ញា ឆ្នាំ២០២៤ | | ៣៣ដុល្លារ |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- លក្ខខណ្ឌចុះឈ្មោះធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន គឺចាប់ពីអាយុ ១៧ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌
- ចំនួនបេក្ខជនដែលអាចទទួលដើម្បីស្នើសុំធ្វើតេស្តគឺចំនួន ៥០នាក់ ក្នុងមួយខែ សម្រាប់ផ្នែកថែទាំ និងកសិកម្ម និងចំនួន ១០០នាក់ ក្នុងមួយខែ សម្រាប់ផ្នែកការងារនៅភោជនីយដ្ឋាន
- ព័ត៌មានអំពីមណ្ឌលសម្រាប់ធ្វើតេស្តមានដូចខាងក្រោម៖
  - ❖ វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI)
    - អាសយដ្ឋាន៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
    - លេខទូរស័ព្ទ៖ +855 12 937 168 / +855 16 862 868 / +855 15 729 123 / +855 12 269 768
- សេវានៃការចុះឈ្មោះធ្វើតេស្តគឺបង់ជូនទៅអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន
- ឯកសារចាំបាច់ដែលត្រូវយកមកជាមួយនៅថ្ងៃធ្វើតេស្ត៖
  - ❖ អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬប័ណ្ណបើកបរ
- សម្រាប់ព័ត៌មានលម្អិត និងការចុះឈ្មោះ សូមចូលទៅគេហទំព័រ https://ac.prometric-jp.com/testlist/ssw/index.html

**បញ្ជាក់៖** កាលបរិច្ឆេទនៃការធ្វើតេស្តខាងលើនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់ចុះឈ្មោះធ្វើតេស្តភាសា និងតេស្តជំនាញសម្រាប់ផ្នែកខាងលើនេះ ជ្រាបជាព័ត៌មាន។

ថ្ងៃ ច ៧ ១០រោច ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

ហេង សួរ

**ចម្លងជូន៖**

-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)

-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់

"ដើម្បីផ្សព្វផ្សាយ"

-ឯកសារ កាលប្បវត្តិ